# ការប្រាស្រ័យទាក់ទងជាមួយអ្នកផ្ដល់សេវារបស់អ្នក

**របៀបដែលអ្នកទាក់ទងជាមួយអ្នកផ្ដល់សេវារបស់អ្នក អាចប៉ះពាល់ដល់គុណភាពនៃការថែទាំដែល អ្នកទទួលបាន។**
ការមានទំនាក់ទំនងល្អគឺជាជំហានដំបូងឆ្ពោះទៅរកទំនាក់ទំនងការងារវិជ្ជមាន។

ដើម្បីប្រាស្រ័យទាក់ទងគ្នាបានល្អ អ្នកត្រូវប្រាប់អំពីតម្រូវការរបស់អ្នកឱ្យបានច្បាស់លាស់ជានិច្ច។ ស្ដាប់ពីរបៀបដែលអ្នកផ្ដល់សេវារបស់អ្នកឆ្លើយតប និងសួរសំណួរអំពីអ្វីដែលអ្នកមិនយល់។

**ចំណាយពេលដើម្បីស្វែងយល់អំពីអ្នកផ្ដល់សេវារបស់អ្នក។**

- សួរអ្នកផ្ដល់សេវារបស់អ្នកថាតើ គាត់ចង់ឱ្យអ្នកហៅគាត់ឈ្មោះអ្វី ហើយប្រើឈ្មោះនោះ។
- សួរអំពីទម្លាប់ណាមួយដែលអ្នកផ្ដល់សេវារបស់អ្នកអាចមាន ដែលអាចប៉ះពាល់ដល់អ្នក ដូចជាការជក់បារី និងនិយាយអំពីទម្លាប់ដែលអ្នកមាន ដែលអ្នកផ្ដល់សេវារបស់អ្នកគួរដឹង។

**ត្រូវប្រាកដថាអ្វីដែលអ្នកកំពុងនិយាយត្រូវបានយល់ ដោយអ្នកផ្ដល់សេវារបស់អ្នក។**

- កុំនិយាយលឿនពេក ឬយឺតពេក។
- ប្រសិនបើអ្នកកំពុងនិយាយជាមួយអ្នកផ្ដល់សេវារបស់អ្នក ហើយគាត់ហាក់ដូចជាមានការភ័ន្តច្រឡំ សូមសួរពួកគេថាតើពួកគេយល់ពីអ្វីដែលអ្នកកំពុងនិយាយដែរឬទេ។ តាមរយៈការសួរអ្នកផ្ដល់សេវារបស់អ្នក អ្នកនឹងដឹងច្បាស់ថាប្រសិនបើគាត់យល់ពីអ្នកនិយាយ ឬបើអ្នកត្រូវការផ្ដល់ព័ត៌មានលម្អិតបន្ថែមទៀត។

**គន្លឹះមានប្រយោជន៍សម្រាប់ការទំនាក់ទំនងល្អ៖**

- រក្សាបណ្ដាញទំនាក់ទំនងបើកចំហ ដើម្បីជៀសវាងការយល់ច្រឡំ។
- វាអាចជួយក្នុងការប្រើការនិយាយលេងសើច និងការអត់ធ្មត់នៅពេលប្រឈមមុខនឹងស្ថានភាពលំបាក។ សំនៀងនៃសម្លេងរបស់អ្នកក៏អាចធ្វើអោយលទ្ធផលប្រសើរឡើងផងដែរ។
- ទទួលខុសត្រូវចំពោះអារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នក និងគោរពចំពោះកង្វល់របស់អ្នកផ្ដល់សេវារបស់អ្នក ដោយប្រើសេចក្ដីថ្លែងថា "ខ្ញុំ" ។

*"ខ្ញុំយល់/ឮ/មានអារម្មណ៍ (បញ្ជាក់ពីបញ្ហា) ។
វាធ្វើឱ្យខ្ញុំមានអារម្មណ៍ (បង្ហាញពីអារម្មណ៍របស់អ្នក) ។
ខ្ញុំត្រូវការ (បញ្ជាក់ពីដំណោះស្រាយដែលអាចធ្វើទៅបាន) ។"*

**សេចក្ដីថ្លែងថា "ខ្ញុំ" ដែលជាគំរូ៖**
"នេះជាលើកទី3 ហើយក្នុងសប្ដាហ៍នេះ ដែលអ្នកមកយឺត 20 នាទី។ ខ្ញុំមានអារម្មណ៍តានតឹង ព្រោះកាលវិភាគរបស់ខ្ញុំត្រូវបានបិទនៅពេលអ្នកមកយឺត។ ខ្ញុំត្រូវការអ្នកមកទីនេះឱ្យទាន់ពេល។"

"ខ្ញុំយល់ថាកិច្ចការនេះពិបាករៀន ប៉ុន្តែ វាធ្វើឱ្យខ្ញុំមានអារម្មណ៍មិនស្រួលនៅពេលអ្នករអ៊ូរទាំ និយាយតិចៗ ។ ខ្ញុំចង់ឱ្យអ្នកសួរខ្ញុំសំរាប់ការណែនាំបន្ថែមទៀត និងឱ្យខ្ញុំដឹងពីអ្វីដែលអ្នកមានអារម្មណ៍ ដូច្នេះយើងអាចរកមធ្យោយដើម្បីដោះស្រាយនូវបញ្ហានេះ។"

រក្សាបណ្តាញទំនាក់ទំនងបើកចំហ និងផ្តោតទៅលើការថែទាំរបស់អ្នក។

- មានភាពរួសរាយរាក់ទាក់ ប៉ុន្តែរក្សាទំនាក់ទំនងរបស់អ្នកប្រកបដោយវិជ្ជាជីវៈតាមដែលអាចធ្វើទៅបាន។ ត្រូវចងចាំថាគាត់នៅទីនោះដើម្បីផ្តល់សេវាកម្ម IHSS សម្រាប់អ្នក។
- អ្នកផ្តល់សេវារបស់អ្នកប្រហែលជាមិនចង់ផ្តល់ព័ត៌មានលម្អិតអំពីជីវិតផ្ទាល់ខ្លួនរបស់គាត់/នាងទេ។ ត្រូវគោរពភាពឯកជនរបស់ពួកគេ។
- ពេលខ្លះភាពខុសគ្នានៃវប្បធម៌អាចប៉ះពាល់ដល់របៀបដែលអ្នកទាក់ទងគ្នា ហើយអាចបង្កើតការយល់ច្រលំ។ និយាយអំពីរឿងទាំងនេះភ្លាមៗ ហើយធ្វើការលើដំណោះស្រាយដែលនឹងបំពេញចិត្តអ្នកទាំងពីរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**